ផ្សារមូលបត្រកម្ពុជា

CSX

ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

លេខ: ០៥៤/១៩

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃ ចន្ទ ៣រោច ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមេសា ឆ្នាំ ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពីការកំណត់កាលបរិច្ឆេទពាក់ព័ន្ធនឹងការបង់គូប៉ុង ឬការប្រាក់

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) មានកិត្តិយសជម្រាបជូនដំណឹងដល់វិនិយោគិនអំពីការកំណត់កាលបរិច្ឆេទពាក់ព័ន្ធនឹងការបង់គូប៉ុង ឬបង់ការប្រាក់ដល់ម្ចាស់សញ្ញាបណ្ណ ដោយក្រុមហ៊ុនចុះបញ្ជីលក់សញ្ញាបណ្ណនៅ ផ.ម.ក. ដូចខាងក្រោម÷

**១. កាលបរិច្ឆេទអិចគូប៉ុង (Ex-Coupon Date) ឬ កាលបរិច្ឆេទអិចអ៊ីនធើរ៉េស (Ex-Interest Date)**÷ គឺជាកាលបរិច្ឆេទដែលត្រូវបានកំណត់យក ០១ (មួយ)ថ្ងៃនៃថ្ងៃជួញដូរមុនកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះម្ចាស់សញ្ញាបណ្ណដែលត្រូវទទួលបានគូប៉ុង ឬការប្រាក់ (Record Date)។ **ប្រសិនបើវិនិយោគិនទិញ សញ្ញាបណ្ណនៅចំថ្ងៃ ឬបន្ទាប់ពីកាលបរិច្ឆេទអិចគូប៉ុង ឬកាលបរិច្ឆេទអិចអ៊ីនធើរ៉េស វិនិយោគិននោះនឹងមិនទទួលបានគូប៉ុង ឬការប្រាក់ពីក្រុមហ៊ុនចុះបញ្ជីឡើយ។ ដូចនេះ ដើម្បីទទួលបានគូប៉ុង ឬការប្រាក់ពីក្រុមហ៊ុនចុះបញ្ជី វិនិយោគិនត្រូវទិញសញ្ញាបណ្ណមុនកាលបរិច្ឆេទ អិចគូប៉ុង ឬកាលបរិច្ឆេទអិចអ៊ីនធើរ៉េស។**

**២. កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះម្ចាស់សញ្ញាបណ្ណដែលត្រូវទទួលបានគូប៉ុង ឬការប្រាក់ (Record Date)**÷ គឺជាកាលបរិច្ឆេទនៃការប្រកាសបញ្ជីឈ្មោះម្ចាស់សញ្ញាបណ្ណដែលមានសិទ្ធិទទួលបានគូប៉ុង ឬការប្រាក់ពីក្រុមហ៊ុនចុះបញ្ជី។ កាលបរិច្ឆេទនេះ ត្រូវបានកំណត់យក ២ (ពីរ)ថ្ងៃ នៃថ្ងៃជួញដូរ មុនកាលបរិច្ឆេទបែងចែកគូប៉ុង ឬការប្រាក់ (Payment Date)។

**៣. កាលបរិច្ឆេទបង់គូប៉ុង ឬការប្រាក់ (Payment Date)**÷ គឺជាកាលបរិច្ឆេទដែលក្រុមហ៊ុនចុះបញ្ជីកំណត់យកដើម្បីបង់គូប៉ុង ឬការប្រាក់ដល់ម្ចាស់សញ្ញាបណ្ណ។ កាលបរិច្ឆេទបង់គូប៉ុង ឬ ការប្រាក់ ត្រូវធ្វើឡើងនៅថ្ងៃជួញដូរ ករណីមិនត្រូវចំថ្ងៃជួញដូរ ត្រូវលើកទៅថ្ងៃបន្ទាប់ដែលជាថ្ងៃជួញដូរ។

អគារ ផ.ម.ក. វិថីព្រះមហាក្សត្រីយានី កុសុមៈ (ផ្លូវ ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (៨៥៥) ២៣ ៩៥ ៨៨ ៨៨ ទូរសារ: (៨៥៥) ២៣ ៩៥ ៥៥ ៥៨ អ៊ីម៉ែល: info@csx.com.kh គេហទំព័រ: http://www.csx.com.kh




**ឧទាហរណ៍÷** ក្រុមហ៊ុន កខគ ដែលជាក្រុមហ៊ុនចុះបញ្ជីលក់សញ្ញាបណ្ណនៅ **ផ.ម.ក.** បានកំណត់កាលបរិច្ឆេទបង់គូប៉ុង ពីរដងក្នុង១ឆ្នាំ គឺនៅថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី៣១ ខែធ្នូ ជារៀងរាល់ឆ្នាំសម្រាប់រយៈពេល៣ឆ្នាំទៅដល់ម្ចាស់សញ្ញាបណ្ណរបស់ក្រុមហ៊ុន។ តើម្ចាស់សញ្ញាបណ្ណណាខ្លះមានសិទ្ធិទទួលបានគូប៉ុងពីក្រុមហ៊ុន កខគ ?

ផ្អែកលើឧទាហរណ៍នេះការកំណត់កាលបរិច្ឆេទពាក់ព័ន្ធនឹងការចែកគូប៉ុងដល់ម្ចាស់សញ្ញាបណ្ណនៃក្រុមហ៊ុន កខគ សម្រាប់ឆ្នាំ២០១៩ គឺ÷

-ការបង់គូប៉ុងលើកទី១ ក្នុងឆ្នាំ២០១៩÷

កាលបរិច្ឆេទអិចគូប៉ុង (Ex-Coupon Date) គឺ÷ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ។ វិនិយោគិនដែលទិញសញ្ញាបណ្ណនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ ឬបន្ទាប់ពីកាលបរិច្ឆេទនេះ នឹងមិនមានសិទ្ធិទទួលបានគូប៉ុងលើកទី១ ក្នុងឆ្នាំ២០១៩នេះនោះទេ តែមានសិទ្ធិទទួលបានគូប៉ុងលើកទី២ និងបន្តបន្ទាប់ប្រសិនបើវិនិយោគិននៅបន្តកាន់កាប់សញ្ញាបណ្ណនោះ។

កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះម្ចាស់សញ្ញាបណ្ណដែលត្រូវទទួលបានគូប៉ុង(Record Date) គឺ÷ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ (ថ្ងៃទី២៩ និង៣០ ខែមិថុនា ឆ្នាំ២០១៩ ដែលចំថ្ងៃចុងសប្តាហ៍ដែលមិនស្ថិតក្នុងថ្ងៃជួញដូរ មិនត្រូវបានរាប់បញ្ចូលនោះឡើយ)។ វិនិយោគិនដែលមានឈ្មោះក្នុងបញ្ជីនៅកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះម្ចាស់សញ្ញាបណ្ណនេះ មានសិទ្ធិទទួលបានគូប៉ុងពីក្រុមហ៊ុន កខគ ។

កាលបរិច្ឆេទបង់គូប៉ុង (Payment Date) គឺ÷ ក្រុមហ៊ុន កខគ បានកំណត់យកថ្ងៃទី៣០ ខែមិថុនា ប៉ុន្តែក្នុងឆ្នាំ២០១៩ កាលបរិច្ឆេទកំណត់យកថ្ងៃទី៣០ ខែមិថុនា ត្រូវចំថ្ងៃអាទិត្យដែលមិនស្ថិតក្នុងថ្ងៃជួញដូរ ធ្វើឱ្យកាលបរិច្ឆេទបង់គូប៉ុង ឬការប្រាក់ត្រូវលើកទៅថ្ងៃបន្ទាប់គឺថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ វិញ។

-ការបង់គូប៉ុង ឬការប្រាក់លើកទី២ ក្នុងឆ្នាំ២០១៩÷

កាលបរិច្ឆេទអិចគូប៉ុង (Ex-Coupon Date) គឺ÷ ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ។ វិនិយោគិនដែលទិញសញ្ញាបណ្ណនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ឬបន្ទាប់ពីកាលបរិច្ឆេទនេះ នឹងមិនមានសិទ្ធិទទួលបានគូប៉ុងលើកទី២ ក្នុងឆ្នាំ២០១៩នេះនោះទេតែមានសិទ្ធិទទួលបានគូប៉ុងឆ្នាំក្រោយបន្តបន្ទាប់ប្រសិនបើវិនិយោគិននៅបន្តកាន់កាប់សញ្ញាបណ្ណនោះ។

កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះម្ចាស់សញ្ញាបណ្ណដែលត្រូវទទួលបានគូប៉ុង (Record Date) គឺ÷ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ (ថ្ងៃទី២៨ និង២៩ ខែធ្នូ ឆ្នាំ២០១៩ ដែលចំថ្ងៃចុងសប្តាហ៍ដែលមិនស្ថិតក្នុងថ្ងៃជួញដូរ មិនត្រូវបានរាប់បញ្ចូលនោះឡើយ)។ វិនិយោគិនដែលមានឈ្មោះក្នុងបញ្ជីនៅកាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះម្ចាស់សញ្ញាបណ្ណនេះ មានសិទ្ធិទទួលបានគូប៉ុង ពីក្រុមហ៊ុន កខគ ។

កាលបរិច្ឆេទបង់គូប៉ុង (Payment Date) គឺ÷ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ។

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

អគារ ផ.ម.ក. វិថីព្រះមហាក្សត្រិយានី កុសុមៈ (ផ្លូវ ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ: (៨៥៥) ២៣ ៩៥ ៨៨ ៨៨ ទូរសារ: (៨៥៥) ២៣ ៩៥ ៥៥ ៥៨ អ៊ីម៉ែល: info@csx.com.kh គេហទំព័រ: http://www.csx.com.kh